ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០៧៥ ព.ណ..ប្រក

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រង ការរៀបចំនិងចាត់ចែង ព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១ .-**

រាល់ការរៀបចំពិព័រណ៍ពាណិជ្ជកម្ម ការតាំងបង្ហាញផលិតផល ការផ្សព្វផ្សាយផលិតផល និងសេវាគ្រប់ប្រភេទ ក្នុងប្រយោជន៍ធ្វើការផ្សព្វផ្សាយ ឬលក់ដូរ ឬការស្វែងរកដៃគូ ដើម្បីរកប្រាក់ចំណេញ ឬដើម្បីបែងចែកផលិតផល ឬសេវា


ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

របស់ខ្លួន សម្រាប់ចរាចរនៅលើទីផ្សារ ទោះបីព្រឹត្តិការណ៍នោះ មានប្រធានបទជាលក្ខណៈទូទៅ ឬប្រធានបទ ជាវិជ្ជាជីវៈ ឬផ្សារណាត់ ត្រូវបានចាត់ទុកជា **ព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម**។

**ប្រការ២ ._**

ការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ទោះបីជាប្រធានបទទូទៅ ឬប្រធានបទវិជ្ជាជីវៈ ឬផ្សារណាត់ ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវឈ្មោះ ឬប្រធានបទ ពេលវេលា ទីតាំងរៀបចំដាក់លាក់ ស្លាកសញ្ញា សម្គាល់ (Logo) និង អាសយដ្ឋានរបស់អ្នករៀបចំ។

**ប្រការ៣ ._**

ព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម។ រាល់ការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយក្រុមហ៊ុនឯកជនក្នុងប្រទេស ឬក្រៅប្រទេស សភាពាណិជ្ជកម្ម សមាគម អង្គការក្រៅរដ្ឋាភិបាល ស្ថានទូត ឬស្ថាប័នរដ្ឋ ត្រូវសុំការអនុញ្ញាតនៅនាយកដ្ឋានកិច្ចការ ពិព័រណ៍ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត។ ពាក្យស្នើសុំរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ត្រូវដាក់ឱ្យបានយ៉ាងតិច ៤៥ ថ្ងៃ មុនពេលព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មត្រូវបើកជាផ្លូវការ។

- ក្នុងករណីមានការផ្លាស់ប្តូរប្រធានបទ ឬឈ្មោះព្រឹត្តិការណ៍ អ្នករៀបចំត្រូវធ្វើលិខិតជូនដំណឹងមកក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ឱ្យបាន ១៥ ថ្ងៃ មុនកាលបរិច្ឆេទ។
- ក្នុងករណីមានការផ្លាស់ប្តូរពេលវេលា ឬទីតាំង ឬខកខាន ឬផ្អាកការរៀបចំព្រឹត្តិការណ៍ អ្នករៀបចំត្រូវធ្វើលិខិតមកក្រសួង ឬមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ស្នើសុំរៀបចំជាថ្មី ដោយលិខិតអនុញ្ញាតលើកដំបូងត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤ ._**

ក្រុមហ៊ុនធ្វើអាជីវកម្មសេវាកម្មរៀបចំ និងចាត់ចែងព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែជាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។ ចំពោះក្រុមហ៊ុនក្រៅប្រទេស សភាពាណិជ្ជកម្ម សមាគម អង្គការក្រៅរដ្ឋាភិបាល (លើកលែងតែស្ថានទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា) ត្រូវបង្ហាញឯកសារតម្កល់ទុកលក្ខន្តិកៈរបស់ខ្លួននៅក្រសួង-ស្ថាប័នពាក់ព័ន្ធ។

**ប្រការ៥ ._**

ព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ឱ្យរៀបចំឡើងដោយរក្សាភាពថ្លៃថ្នូរ របៀបរៀបរយ ស្មោះត្រង់ក្នុងការប្រកួតប្រជែងក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារសេរី។ ការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ត្រូវបានកំណត់តាមលក្ខខណ្ឌ ដូចខាងក្រោម៖

- ពេលវេលានៃការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម នឹងផ្តល់អាទិភាពដល់អ្នកដែលបានដាក់ពាក្យស្នើសុំមុន (អ្នកមកមុន ទទួលបានសេវាមុន)។
- ព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ត្រូវបានអនុញ្ញាតឱ្យរៀបចំយ៉ាងយូរបំផុតត្រឹមចំនួន ០៥(ប្រាំ) ថ្ងៃ។
- មិនអនុញ្ញាតឱ្យរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ដែលមានប្រធានបទ ឬឈ្មោះដូចគ្នា ឬប្រហាក់ប្រហែលគ្នា ក្នុងពេលវេលាជាមួយគ្នា។ ការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ដែលមានប្រធានបទ ឬឈ្មោះដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដោយអ្នករៀបចំ ឬចាត់ចែងផ្សេងគ្នា នឹងត្រូវបានអនុញ្ញាតឱ្យរៀបចំ ឡើងក្រោយរយៈពេល ០២(ពីរ) ខែ បន្ទាប់ពីព្រឹត្តិការណ៍ទី១ បានបញ្ចប់។
- មិនអនុញ្ញាតឱ្យរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ក្នុងទីតាំងតែមួយ ពេលវេលាដូចគ្នា ឬត្រួតថ្ងៃគ្នា។
- មិនអនុញ្ញាតឱ្យប្រើសញ្ញាសម្គាល់ព្រឹត្តិការណ៍ (Logo) ដែលមានលក្ខណៈដូចគ្នា ឬប្រហាក់ប្រហែលគ្នា។

- មិនអនុញ្ញាតឱ្យរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ដែលមានប្រធានបទ ឬឈ្មោះ ដែលបានចុះបញ្ជីជាពាណិជ្ជនាម ឬពាណិជ្ជសញ្ញា ឬមានលក្ខណៈជាតិ ឬមានលក្ខណៈអន្តរជាតិ ។

**ប្រការ៦ ._**

ព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ដែលមានការផ្សព្វផ្សាយពាណិជ្ជកម្ម ការលក់ដូរទំនិញ និងសេវាគ្រប់ប្រភេទមានលក្ខណៈភូតកុហក បំភ្លើសការពិត ក្លែងបន្លំ ឬធ្វើឱ្យមានការភ័ន្តច្រឡំអំពីគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា ឬការធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍សង្គម ឬប៉ះពាល់ដល់នយោបាយ ឬទំនាក់ទំនងការទូត ត្រូវបានហាមឃាត់ទាំងស្រុង។

**ប្រការ៧ ._**

សំណុំឯកសារតម្រូវសម្រាប់សុំលិខិតអនុញ្ញាតរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម មានដូចខាងក្រោម៖

- ពាក្យស្នើសុំការអនុញ្ញាតរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ចំនួន ០១ ច្បាប់ (មានគំរូស្រាប់)
- ឯកសារផ្លូវច្បាប់ដែលបានទទួលស្គាល់ ឬចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម
- លិខិតអនុញ្ញាតទីតាំងរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ពីអាជ្ញាធរមូលដ្ឋានរាជធានី-ខេត្ត។

**ប្រការ៨ ._**

លិខិតអនុញ្ញាតឱ្យរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម មានសុពលភាពតែមួយលើកគត់ សម្រាប់មួយព្រឹត្តិការណ៍។

**ប្រការ៩ ._**

ក្រុមហ៊ុនឯកជនក្នុងប្រទេស ឬក្រៅប្រទេស សភាពាណិជ្ជកម្ម សមាគម អង្គការក្រៅរដ្ឋាភិបាល ស្ថានទូត ឬស្ថាប័នរដ្ឋ ដែលសុំការអនុញ្ញាតរៀបចំ និងចាត់ចែងព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម (ក្នុងគោលបំណងរកប្រាក់ចំណេញ) ត្រូវមានកាតព្វកិច្ចបង់កម្រៃសេវាសាធារណៈជូនរដ្ឋ ដូចមានចែងក្នុងកម្រងសេវាសាធារណៈក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមលេខ ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

មូលដ្ឋានសម្រាប់គិតកម្រៃសេវាសាធារណៈ រួមមាន៖

១- សេវាចេញលិខិតអនុញ្ញាតឱ្យរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ចំនួន ១,៤០០,០០០ (មួយលានបួនរយពាន់) រៀល

២- កម្រៃនៃការគ្រប់គ្រង និងចាត់ចែងព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម៖

- វិស័យទូទៅ (ប្រធានបទពាក់ព័ន្ធនឹងវិជ្ជាជីវៈ) ចំនួន ១០០,០០០ (មួយរយពាន់) រៀល/មួយស្តង់
- ព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ដែលមានប្រធានបទបម្រើវិស័យកសិកម្មជាលក្ខណៈអន្តរជាតិ ចំនួន ២០,០០០ (ម្ភៃពាន់) រៀល/មួយស្តង់។

**ប្រការ១០ ._**

ការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ដែលគ្មានការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម ឬមិនគោរពតាមប្រការដែលមានចែងក្នុងប្រកាសនេះ នឹងត្រូវបានចាត់ទុកថាជាការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មមិនស្របច្បាប់។ ក្នុងករណីនេះ ព្រឹត្តិការណ៍នោះនឹងត្រូវផ្អាក ឬបិទទាំងស្រុង និង/ឬ ត្រូវពិន័យជាប្រាក់ពី ៥,០០០,០០០ (ប្រាំលាន) រៀល ដល់ ១០,០០០,០០០ (ដប់លាន) រៀល ដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ១១ ._**

នាយកដ្ឋានកិច្ចការពិព័រណ៍ មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ត្រូវមានភារកិច្ចតាមដានការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម រាប់ចំនួនស្តង់ដែលបានរៀបចំ និងប្រមូលកម្រៃនៃការគ្រប់គ្រង និងចាត់ចែងព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម ពីអ្នករៀបចំព្រឹត្តិការណ៍ ដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ។

**ប្រការ១២ ._**

ប្រកាស និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៣ ._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ២ រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ១៣
- ឯកសារ កាលប្បវត្តិ